# អត្ថបទ
# អ្នកនិពន្ធ នូ ហាច

ដោយលោក **ឃិន យ៉ង់** នាយកដ្ឋានកិច្ចការទូទៅ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១- ជីវប្រវត្តិអ្នកនិពន្ធ

លោក នូ ហាច ជាអ្នកនិពន្ធមួយរូបដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ក្នុងជំនាន់ស្របាលគ្នានឹងលោក រីម គីន ដែរ។ គាត់ក៏បានទទួលការសិក្សាពីសាលាទំនើបដែរ ហើយបានតែងនិពន្ធស្នាដៃប្រលោមលោកជាច្រើនក្នុងសម័យអាណាព្យាបាលបារាំង និងដើមសម័យឯករាជ្យ ជាអាទិ៍រឿងផ្កាស្រពោនដែលត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់មធ្យមសិក្សាបឋមភូមិ ។

លោក នូ ហាច ប្រសូតនៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ ចំពោះកាលបរិច្ឆេទកំណើត របស់លោកមានមតិពីរប្លែកគ្នាលើឆ្នាំកំណើត គឺ៖

ប្រភពពីបណ្ឌិត ឃីង ហុកឌី អ្នកនិពន្ធ នូ ហាច កើតពីថ្ងៃ២៦ មិថុនា ១៩១៦ នៅភូមិកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ លោកនូ ហាច ជាបុត្រារបស់លោកតា ឃួន នូ និង លោកយាយ ឱរ មួច[១]។

ប្រភពពីលោក ស មុនី លោកសាស្ត្រាចារ្យ អុក ចួន និងទស្សនាវដ្តីអ្នកនិពន្ធខ្មែរបញ្ជាក់ថា លោក នូ ហាច កើតនៅថ្ងៃទី២០ មិថុនា ១៩១៨ នៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ បិតារបស់លោកឈ្មោះ ឃួន នូ មាតាឈ្មោះ ឃួន មុច[២]។

លោក ស មុនី បញ្ជាក់ថា បិតារបស់លោកឈ្មោះ ឃួន នូ មាតាឈ្មោះ ឃួន មុច។

តាមរយៈការសម្ភាសន៍ផ្ទាល់ជាមួយលោកតា រី ទី (តាន់ ទី) អាយុ ៧៩ឆ្នាំ ដែលជាប្អូនសាច់ឆ្ងាយ របស់លោក នូ ហាច មានប្រសាសន៍ថា ឪពុកលោក នូ ហាច ឈ្មោះ អ៊ុំនៅ(នូ?) មានដើមកំណើតជាអ្នក កំពង់ឆ្នាំង បានប្រពន្ធជាអ្នកកំពង់ព្រះ ឈ្មោះ អ៊ុំមួច ប្រកបរបរធ្វើស្រែមាននង្គ័លពីរ បី ដែលជាកេរខាងឪពុក ក្មេក និងស្រែចាប់ព្រៃនៅ បឹងឫស្សី[៣]។

---

[១].រៀបរៀងដោយបណ្ឌិតសភាចារ្យ ឃីង ហុកឌី អារម្ភកថាដោយបណ្ឌិតសភាចារ្យ ឃីង ហុកឌី Voir Khing Hoc Dy ***Ecrivains et expressions littéraires du Cambodge au XXéme siécle*** volume 2 L'Harmattan Paris 1993 p.46.

[២].គឹម សែត ទំព័រទី២៥៥-២៥៧ (ផ្នែកនេះអ្នកនិពន្ធបានលើកយកអត្ថបទលោក ស មុនី មកបញ្ចូលតែម្តង)

-អ៊ុក ចួន សាលាគរុវិជ្ជាជាន់ខ្ពស់ «សំរាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ» ដឯម ទំព័រទី៤១

-សមាគមអ្នកនិពន្ធខ្មែរ *ប្រវត្តិអ្នកនិពន្ធខ្មែរ* ក្នុង ***ទស្សនាវដ្តីអ្នកនិពន្ធខ្មែរ*** ឆ្នាំទី២ លេខ៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ទំព័រទី១៣។

[៣].ការសម្ភាសន៍ជាមួយលោកតា រី ទី (តាន់ ទី) អាយុ ៧៩ឆ្នាំ ជាប្អូនសាច់ឆ្ងាយរបស់លោក នូ ហាច ស្តីពី «**ជីវប្រវត្តិលោក នូ ហាច**» នៅឃុំកំពង់ព្រះ ថ្ងៃទី៧ ខែមករា ឆ្នាំ២០០២ វេលាម៉ោង ៩៖៤០នាទី។

មានការបកស្រាយផ្សេងគ្នាពីចំនួនបងប្អូនបង្កើតរបស់លោក នូ ហាច។ តាមរយៈការបទសម្ភាសន៍ជាមួយលោកយាយ អួន ឆែម អាយុ៨៨ឆ្នាំ ដោយក្នុងទស្សនាវដ្តីប្រជាប្រិយបានប្រាប់ឱ្យដឹងថា ក្នុងរឿង «ផ្កាស្រពោន» តួអង្គ ប៊ុន ធឿន គឺជារូបលោក នូ ហាច ត្រូវជាក្មួយសាច់ថ្លៃមានឪពុកឈ្មោះ ឃួន នៅ និងម្តាយឈ្មោះ មួច (ទាំងអស់គ្នាស្លាប់អស់ហើយ)។ លោកយាយបន្តថា លោក នូ ហាច មានបងប្អូនប្រុសស្រីទាំងអស់ ដប់ពីនាក់ (ស្រីបីនាក់) ហើយសព្វថ្ងៃនៅរស់តែបួននាក់ (ស្រីពីរនាក់) រស់នៅសហរដ្ឋអាមេរិក និងថៃ គឺមាន ឈ្មោះ គុយ, កណ្តៀន, វ៉ាត់ និងយឿត[៤]។ បទសម្ភាសន៍នេះ លោកយាយ អ៊ួន ឆែម ក៏បានផ្តល់ផងដែរដល់កាសែតរស្មីកម្ពុជា តែគ្មានបញ្ជាក់ថាលោក នូ ហាច មានបងប្អូននៅប្រទេសថៃទេ ក្នុងពេលបច្ចុប្បន្ន[៥]។

តាមការជួបសម្ភាសន៍ផ្ទាល់ជាមួយអ្នកមីង រុំ ឌី អាយុ៤៦ឆ្នាំ មុខរបរធ្វើស្រែ ជាកូនស្រីលោកយាយដៀង (ប្អូនជីទួតមួយលោក នូ ហាច) ស្នាក់នៅថែរក្សាផ្ទះលោក នូ ហាច បានឱ្យដឹងថាលោក នូ ហាច មានបងប្អូនប្រាំបួននាក់ស្រីបីនាក់ (ប្រុសប្រាំមួយនាក់) ដែលមានរូបលោក ផ្ទាល់ ជាកូនច្បង និងប្អូនៗប្រាំបីនាក់ ទៀតគឺ ៖

១. ឈ្មោះ ឈឿន (មានប្រពន្ធជាអ្នកសៀមរាប)

២. ឈ្មោះ ឈឿយ (ស្រី)

៣. ឈ្មោះ ឆោម

៤. ឈ្មោះ ឈៀត

៥. ឈ្មោះ កណ្តៀន

៦. ឈ្មោះ យឿត (ស្រី)

៧. ឈ្មោះ វ៉ាត់ (ស្រី)

៨. ឈ្មោះ គុយ (ទៅមកបាងកក-ភ្នំពេញ ជាកូនពៅ) [៦]។

លោកតា តាន់ ទី បានបញ្ជាក់ថា លោក នូ ហាច បានរៀបការជាមួយស្រីម្នាក់ឈ្មោះ រ៉ែម (មិនដឹងកាលបរិច្ឆេទ) ជាអ្នកនៅខេត្តសៀមរាប ក្រោយពីស្នេហាខកបំណងជាមួយគូស្នេហ៍ចាស់ (នាងវិធាវី) ដោយនាងត្រូវម្តាយលើកឱ្យកូនអ្នកមាន ជាថៅកែដើរកាណូត។ ជីវិតអាពាហ៍ពិពាហ៍របស់លោក បានផ្តល់កំណើតឱ្យកូនពីររូប ដែលបច្ចុប្បន្នកំពុងរស់នៅសហរដ្ឋអាមេរិក។ ប្អូនៗលោក នូ ហាច ទាំងអស់សុទ្ធតែប្រើត្រកូល ឃួន ដែលជាឈ្មោះជីតាទៅតាមទម្លាប់ប្រើឈ្មោះរបស់ខ្មែរ លើកលែងតែលោក នូ ហាច ជាកូនច្បងមានត្រកូល នូ ទៅតាមឈ្មោះឪពុកទៅវិញ។

---

[៤] .សូមមើលទស្សនាវដ្តីប្រជាប្រិយ ឆ្នាំទី០៨ លេខ១៩២ ថ្ងៃទី១១-២០ មករា ២០០២ «**ដំណើររឿងរបស់តួអង្គ ប៊ុនធឿន គឺជាជីវិតពិតរបស់អ្នកនិពន្ធ នូ ហាច**» ទំព័រទី៣២-៣៣។

[៥].សូមមើលកាសែតរស្មីកម្ពុជា លេខ២៥៥៨ ថ្ងៃសៅរ៍ ទី២២ ខែកញ្ញា ឆ្នាំ២០០១ «**ឃុំកំពង់ព្រះ ប្រវត្តិរឿងប៊ុនធឿន-វិធាវី**» ទំព័រ៦១-៦៦។

[៦]. ការសម្ភាសន៍ជាមួយអ្នកមីង រុំ ឌី អាយុ ៤៦ឆ្នាំ មុខរបរធ្វើស្រែ ជាកូនស្រីលោកយាយ ដៀង (ប្អូនជីទួតមួយ លោក នូ ហាច) ស្នាក់នៅថែរក្សាផ្ទះលោក នូ ហាច បានឱ្យដឹងថា «ជីវប្រវត្តិលោក នូ ហាច» នៅផ្ទះលោក នូ ហាច នៅឃុំកំពង់ព្រះ នាថ្ងៃច័ន្ទ ទី៧ ខែមករា ឆ្នាំ២០០២។

តាមរយៈព័ត៌មានពីលោកតា តាន់ ទី ក៏ដូចជាអ្នកមីង ឌុំ រី បានឱ្យដឹងថាលោក នូ ហាច ក្រោយពេលទៅធ្វើការនៅភ្នំពេញ មានមុខមានមាត់មក លោកបានមកធ្វើផ្ទះក្បឿងពីរខ្នង ត្រង់ទីតាំងផ្ទះរបស់ឪពុកម្ដាយ គាត់នៅភូមិ-ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅទីក្រុងភ្នំពេញ លោក នូ ហាច មានផ្ទះមួយដែលទីតាំងផ្ទះនោះ បច្ចុប្បន្នក្លាយជាផ្នែកមួយនៃយានដ្ឋានជួសជុលរថយន្ត នួន សំណាង (ផ្ទះលេខ៣៤ ផ្លូវ លេខ៩៥, ផ្លូវខាងលិចស្របជាមួយមហាវិថីព្រះមុនីវង្ស ក្រោយម៉ុមភ្លើង ខាងជើងភោជនីយដ្ឋានក្រពើ )។ លោកតា ទា លឹមហេង អាយុ៦៥ឆ្នាំ ស្នាក់នៅផ្ទះលេខ១៦ ផ្លូវលេខ១០៥ សង្កាត់ បឹងព្រលឹត ខណ្ឌ៧មករា បញ្ជាក់ថា កាលពីមុនសម័យសង្គ្រាម គេហដ្ឋាននេះជារបស់លោក នូ ហាច មានចារឹកអក្សរ នូ ហាច នៅលើបង្គោលរបង។ ផ្ទះលោក នូ ហាច នេះសង់ឡើងជាលក្ខណៈថ្មក្រោម លើឈើ ប្រក់ក្បឿង។ ផ្ទះនេះនៅជាប់របងគ្នាជាមួយផ្ទះរបស់លោក យូ ហេង អតីតរាជអង្គរក្សព្រះបាទ សុរាម្រិត, អនុរដ្ឋលេខាធិការទទួលភារៈខាងនគរបាលព្រះរាជាណាចក្រ របស់គណៈរដ្ឋមន្ត្រីសង្គមលើកទី១ នាសម័យសង្គមរាស្ត្រនិយម។ អក្សរចារឹកលើរបងទើបត្រូវគេបំផ្លាញក្នុងពេលប៉ុន្មានឆ្នាំមុននេះ។ ក្នុងពេលបំពេញបេសកកម្មជាទីប្រឹក្សាស្ថានឯកអគ្គរាជទូតប្រទេសកម្ពុជា នាទីក្រុងបាងកក និងជាតំណាងអចិន្ត្រៃយ៍ នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេ នាក្រុងបាងកក លោក នូ ហាច មានទីលំនៅនាទីក្រុងបាងកក។

លោកតា តាន់ ទី បញ្ជាក់ថា ជីវិតបឋមវ័យរបស់លោក នូ ហាច បានចាប់ផ្ដើមការសិក្សាដំបូង ដោយការចូលរៀននៅសាលាវត្ត ក្នុងវត្តកំពង់ព្រះ ដែលស្ថិតនៅក្បែរផ្ទះ លុះក្រោយមកក៏បានទៅរៀននៅសាលាឯទីរួមខេត្ត[៧]។

តាមរយៈឯកសារបណ្ឌិត ឃីង ហុកឌី កាលពីវ័យកុមារលោក នូ ហាច បានទទួលការសិក្សាតាម បែបប្រពៃណីនៅវត្តក្នុងភូមិ ហេតុចេះអានអក្ខបទសាស្ត្រាស្លឹករឹតបានយ៉ាងស្ទាត់។ គាត់បានប្រឡងជាប់ចូលរៀនថ្នាក់ទី៦ នៅអនុវិទ្យាល័យស៊ីសុវត្ថិ ក្នុងឆ្នាំ១៩៣២។ គាត់បានទទួលសញ្ញាប័ត្រមធ្យមសិក្សាប័ត្រភាគទីមួយនៅឆ្នាំ១៩៣៩[៨]។

ដោយស្ថិតក្នុងគ្រួសារដែលមានឪពុក និងឪពុកធំ ជាអ្នកចេះដឹងខាងអក្សរសាស្ត្រជាដើមនោះ លោក នូ ហាច មានវាសនាបានទទួលការសិក្សាក្រោមការជំរុញលើកទឹកចិត្តដោយយកចិត្តទុកដាក់ឱ្យខំ រៀនសូត្រជាខ្លាំង។ ក្នុងការសិក្សានេះលោក នូ ហាច បានទទួលការណែនាំឱ្យស្រឡាញ់អក្សរសាស្ត្រតាំងពីកុមារភាព ដោយលោកឃួន នៅ ជាបិតា និងលោកឱរ ស៊ិន ជាឪពុកធំ[៩]។

ក្នុងវ័យសិក្សា លោក នូ ហាច ជាអ្នកស្រវាស្រទេញក្នុងការសិក្សា ទោះបីជាពេលត្រឡប់ទៅភូមិកំណើតពេលបុណ្យទាន ឬវិស្សមកាលម្ដងៗ លោកតែងតែអានសៀវភៅជានិច្ច។ លោកតា តាន់ ទី រំឭកពី លោក នូ ហាច ថា ពេលចូលឆ្នាំ វាកង មកលេងប្អូនៗនៅឯស្រែ គាត់កាន់សៀវភៅរឿង ឬសៀវភៅមេរៀនតាមខ្លួនជាប់ ពេលសួរគាត់ថា បងឯងខំរៀនយ៉ាងណា? គាត់ឆ្លើយថា ឱ្យអញទៅលេងឯណាទៅ អញទៅនិយាយនឹងគេខាងក្រៅ មិនដឹងទៅនិយាយរឿងអី បើមើលសៀវភៅមិនសូវអផ្សុក អញមើលសៀវភៅបានសប្បាយ រៀនមើលរឿង វាមិនអផ្សុក...។

---

[៧]. ការសម្ភាសន៍ជាមួយលោកតា រី ទី ស្ដីពី «ជីវប្រវត្តិលោក នូ ហាច» ដ.ឯ.ម។

[៨]. Voir Khing Hoc Dy ***Ecrivains et expressions littéraires du Cambodge au XXéme siécle*** Op. cit. p. 46.

[៩]. នូ ហាច ***មាលាដួងចិត្ត*** ដ.ឯ.ម ទំព័រ គ។

លោក នូ ហាច ជាមនុស្សសុភាពរាបសារ មិនចេះវាយឫក ពេលសម្រាកវិស្សមកាលត្រឡប់មកផ្ទះម្តងៗ គាត់តែងចុះជួយធ្វើស្រែ ឪពុកម្តាយ បងប្អូនដោយមិនប្រកាន់ខ្លួនឡើយ។ គាត់ជាមនុស្សរួសរាយរាក់ទាក់ជាមួយញាតិមិត្តជិតខាង ចេះជួយគ្នាគ្រាមានការងារពឹងពាក់ ទុក្ខធុរៈផ្សេងៗ។

## ២- រចនាបថអ្នកនិពន្ធ

ក្នុងសាដៃរបស់លោក លោក នូ ហាច បានស្ទាបនាតាមរចនាបថមួយប្លែកពីលោក ញ៉ុក ថែម ក្នុង រឿងកុលាបប៉ៃលិន។ ទំរង់ភាសា «ផ្កាស្រពោន» មានលក្ខណៈអណ្តែតអណ្តូង តាមបែបភាសាកវី។ ទាំងរចនាពាក្យទាំងរចនាឃ្លា សុទ្ធសឹងជាភាសាសាមញ្ញ តែមានសភាពថ្លៃថ្នូរ ទន់ភ្លន់ និងពីរោះជាប់ចិត្ត។

## ៣- ឥទ្ធិពលដែលអ្នកនិពន្ធទទួលបាន

ការដែលក្លាយទៅជាអ្នកនិពន្ធល្បីមួយរូប ជាប្រការលំបាក។ លោក នូ ហាច ជាអ្នកនិពន្ធខ្មែរមួយរូបដែលមានឈ្មោះល្បីតាមរយៈស្នាដៃតែមួយចំនួនតូចតែប៉ុណ្ណោះ។ រឿងផ្កាស្រពោន ជាស្នាដៃដំបូងរបស់លោកដែលទទួលការគាំទ្រពីសំណាក់មជ្ឈដ្ឋានទូទៅជាច្រើន។ តាមរយៈប្រសាសន៍លោកតា តាន់ ទី បានឱ្យដឹងថា លោកតានូ ដែលជាឪពុកលោក នូ ហាច នៅកំពង់ព្រះជាអ្នកចេះដឹងអក្សរសាស្ត្រ អ្នកកំពង់ព្រះរាប់រក ពឹងពាក់ឱ្យធ្វើសំបុត្រស្នាមជាភាសាខ្មែរ ចេះតែងកំណាព្យ អានកាសែតបាន តែលោកមិនបានប្រកបរបរជាអ្នករាជការទេ។ ពត៌មាននេះអាចឱ្យយើងសន្និដ្ឋានថា ក្នុងការសិក្សាតែងនិពន្ធ លោក នូ ហាច បានទទួលមត៌កខ្លះពីបិតាលោក គឺឧបនិស្ស័យក្នុងការសិក្សា ទេពកោសល្យក្នុងការតែងនិពន្ធ។

តាមការសាកសួរចំពោះអ្នកនិពន្ធរៀមច្បងខ្លះៗដូចលោក នូ ហាច នៅឆ្នាំ១៩៧០ លោកបានបញ្ជាក់ប្រាប់ដោយត្រង់ថា លោកមានកំណើតនៅបាត់ដំបង បានស្គាល់អក្សរសាស្ត្រថៃច្បាស់ ព្រោះលោកចេះអាន និងយល់អត្ថបទថៃ ដូចនេះលោកបានទទួលឥទ្ធិពលវប្បធម៌នេះខ្លះ ព្រោះអត្ថបទប្រលោមលោកមាននៅស្រុកថៃ មុនស្រុកខ្មែរយើង ហើយជាពិសេសលោកបានទទួលឥទ្ធិពលពីអក្សរសាស្ត្របារាំងថែមទៀត អ្នកនិពន្ធបារាំងដែលលោកចូលចិត្តជាងគេ គឺ អាលហ្វុង ដូដេ (*Alphonse Daudet*)[១០]។ លោក អាលហ្វុង ដូដេ ជាអ្នកនិពន្ធបារាំងមួយរូប កើតនៅឆ្នាំ១៨៤០ ហើយស្លាប់ទៅវិញនៅឆ្នាំ១៨៩៧។ គាត់ក្លាយជាអ្នកនិពន្ធល្បីល្បាញ ដោយការតែងនិពន្ធរឿងព្រេងដោយមានភាពល្បីល្បាញនៅក្នុងខេត្តកំណើតរបស់គាត់ ដូចជារឿង *Lettres de mon moulin* និពន្ធនៅឆ្នាំ១៨៦៦។ នៅក្នុងខ្សែរឿង *Tartarin* ដែលមានជាពិសេសការផ្សងព្រេងរបស់ *Tartarin* នៃ *Tarascon* និពន្ធនៅឆ្នាំ១៨៧២ គាត់សរសេរបែបជារឿងព្រេងរីករាយនៃមនុស្ស ក្មេងក្លាងដែលមានអាកប្បកិរិយាផ្ទុយស្រឡះជាមួយការពិតជម្មតានៅលើធាកងស្រុកកំណើត។ ប្រលោមលោកដែលគាត់ផ្សព្វផ្សាយជាបន្តបន្ទាប់មកទៀត (ដូចជារឿង *Sapho* និពន្ធនៅឆ្នាំ១៨៨៤) ភ្ជាប់ទៅនឹងភាពប្រាកដនិយមរបស់ *Zola* តាមវិធីសម្តែងគំនិត (ទាក់ទាញដល់) អ្នកមានអារម្មណ៍ចំពោះអក្សរសាស្ត្រ សិល្បៈ និងសិល្បករអណ្តែតអណ្តូង ។

---

[១០]. យឹង ហុកឌី ***ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ*** Éditions L'Harmattan, Paris, FRANCE, 1997, p. 166.

តាមរយៈរឿងផ្កាស្រពោន អ្នកនិពន្ធបានបង្ហាញពីស្ថានភាពសិស្សសាលាដែលធ្វើដំណើរតាមរថភ្លើងចេះច្រៀងទំនុកបារាំងដែលគេធ្លាប់ឮអ្នកលេងកុនឈ្មោះ ទីណូ រ៉ូសស៊ី ច្រៀង[១១]។ លោក ទីណូ រ៉ូសស៊ី កើតនៅឆ្នាំ១៩០៧ នៅ *Ajaccio* ស្លាប់នៅឆ្នាំ១៩៨៣។ លោកជាសិល្បករអណ្ដែតអណ្ដូងរបស់បារាំង។ លោកជាតួឯកនៅលើឆាកតន្ត្រី, ស្ថានីយ៍វិទ្យុ, ជាតារាឯកភាពយន្តលើសពី២៥រឿង ហើយក៏ជាអ្នកអត្ថាធិប្បាយផងដែរនៅលើឆាកក្នុងស្នាដៃនិពន្ធរឿងល្ខោនដែលសម្ដែងដោយតួរីករាយអមទៅដោយបទភ្លេងពិរោះៗ។ ជាប់ចិត្តនឹងប្រភេទសិល្បៈដែលនាំឱ្យគាត់មានភាពល្បីល្បាញដល់ឆ្នាំ១៩៣៣ ទីណូ រ៉ូសស៊ី ឈរជើងជាសិល្បករចម្រៀងបារាំង ដែលមានប្រជាប្រិយភាពខ្លាំង រហូតដល់ពេលស្លាប់ ដោយគាត់មានសំឡេងធំពិសេសនៃមនុស្សប្រុស[១២]។

ឥទ្ធិពលដែលទទួលបានពីរឿង ប៉ូល និងវៀហ្ស៊ីនី "នាងនឹកឃើញកាលដែលប៊ុនធឿន និទានរឿង «ប៉ូល និងវៀហ្ស៊ីនី» ប្រាប់នាង។ ថ្ងៃនោះឯង នាងបានហៅសំឡាញ់នាងជាល្បែងថា «បងប៉ូលៗ» ប៊ុនធឿន ក៏ឆ្លើយហៅនាងថា «អូនវៀហ្ស៊ីនី» វិញ ។ ក្នុងរឿង មាលាដួងចិត្ត អ្នកនិពន្ធបានបង្ហាញពីកវីអ្នកនិពន្ធបរទេស ជាអាទិ៍ អ័លហ្វ្រិដ ដឺ មុស្សេត៍ ម្ចាស់អត្ថបទកំណាព្យ ឡឺសូល អត្ថបទកាព្យរបស់ *H de R* ប្រលោមលោកភាពយន្តបារាំងរឿងទ្វារចង្អៀត របស់ អង់ដ្រេ ហ្ស៊ីដ (*La PORTS d' André Gide*)។ អង់ដ្រេ ហ្ស៊ីដ កើតនៅឆ្នាំ១៨៦៩ ស្លាប់នៅឆ្នាំ១៩៥១ ជាអ្នកនិពន្ធបារាំង ជាក្មួយរបស់លោក ឆាល ហ្ស៊ីដ។ លោកច្រើនសរសេរជាអត្ថបទសារណាស្រាវជ្រាវ និងអត្ថបទទិតៀន ជាងសរសេរប្រលោមលោក។ គាត់ជាអ្នកមានមុខម្នាក់ក្នុងចំណោមអ្នកដែលមានឥទ្ធិពលខ្លាំងនៅក្នុងវិស័យអក្សរសាស្ត្របារាំងទំនើប ដោយបង្ហាញឱ្យឃើញច្បាស់ជាសាធារណៈក្រោយសង្គ្រាមឆ្នាំ១៩១៤ ដោយសារការចេញផ្សាយ ទស្សនាវដ្ដីបារាំងថ្មី (*Nouvvelle revue Française*) ដែលគាត់ជាស្ថាបនិកម្នាក់។ គាត់ក្លាយជាគ្រូ (អ្នកនិពន្ធគំរូម្នាក់ដែលគេតែងរឭកនឹកឃើញគ្រប់ជំនាន់) មានឥទ្ធិពលរហូតទៅដល់ការតែងនិពន្ធអត្ថបទហួសពីការពិតនិយម (*Surréalisme*) និងអត្ថិភាពនិយម ដោយធ្វើការវិភាគលើ (*acte garatuit*) *nottamment* ។ បញ្ហារបស់តួអង្គជាស្នូលនៃស្នាដៃរបស់គាត់ បញ្ជាក់បង្ហាញឱ្យឃើញភាពសាហាវជាឯកត្តបុគ្គលនិយម និងការស្រាវជ្រាវងប់ងល់នៃភាពស្និទ្ធស្នាលមួយ។ គេត្រូវស្គាល់ស្នាដៃសាកល្បងរបស់គាត់ ដូចជា *Les Nourritures terrestres* និពន្ធឆ្នាំ១៨៩៧ ជាស្នាដៃសម្រាយ អណ្ដែតអណ្ដូងដែលក្លាយជាសៀវភៅសំណប់ (អានប្រចាំថ្ងៃ) របស់យុវជនជំនាន់ក្រោយ។ ស្នាដៃសាកល្បងចុងក្រោយ គឺរឿង *Les Nouvelles Nourritures* ជាសញ្ញានៃការវិវត្តន៍ផ្នត់គំនិតរបស់គាត់។ ក្នុងចំណោម ប្រលោមលោក រឿង *L'Immoraliste* និពន្ធឆ្នាំ១៩០២ រឿង *la Porte étroite* និពន្ធឆ្នាំ១៩០៩ រឿង *les Caves du Vatican* និពន្ធឆ្នាំ១៩១៤ បទមហោរី ឬបទគង្វាលចៀម ឬបទស្រុកស្រែចម្ការ (*la Symphonie pastrorale*) និពន្ធឆ្នាំ១៩១៩ រឿង *les Faux-monnayeurs* និពន្ធឆ្នាំ១៩២៦ ដែលក្នុងនោះបកស្រាយការស្រាវជ្រាវយ៉ាងសំខាន់តាមលំនាំរឿង និងជីវប្រវត្តិផ្ទាល់ខ្លួនក្នុង រឿង *Si le grain ne meurt* និពន្ធឆ្នាំ១៩២៦ ការទិតៀនយ៉ាងប៊ិនប្រសប់ (*Pretexte* ឆ្នាំ១៩៣០, *Nouveaux Prêtextes* ឆ្នាំ១៩១១, *Incidences* ឆ្នាំ១៩២៤) ហ្ស៊ីដ បានឈានទៅរកការតែងនិពន្ធផ្នែកល្ខោន (រឿង *Philoctète* ឆ្នាំ១៨៩៩ រឿង *Œdipe* ឆ្នាំ១៩៣០)។ រយៈពេលប្រហែលជិត៤០ឆ្នាំ គាត់បាន យកលំនាំ

---

[១១]. សូមមើល នូ ហាច ***ផ្កាស្រពោន*** រោងពុម្ពរស្មី ក្រសួងសិក្សាធិការជាតិ ភ្នំពេញ គ.ស ១៩៦០ ទំព័រទី២-៣។

[១២]. Voir GEORGES PASCAL ***NOUVELLE ENCYCLOPEDIE BORDAS VIII*** compression / Europe 1985, p.4842.

តាមនិងរៀបចំការសម្តែងដើម្បី *J-L Barrolt* រឿង *les Procès de Kafka*។ ក្នុងចំណោមអ្នកនិពន្ធបរទេសជាច្រើនដែលជាអ្នកមនុស្សនិយម ជានិច្ចកាលតែងមានគំនិតចង់ដឹងចង់យល់ បានលើកសរសើរលោកស្មើនឹង *Dostoïevski* ឬ *Shakespeare*។ សារពត៌មានជាកម្មសិទ្ធិផ្ទាល់ខ្លួន បានចេញផ្សាយចាប់តាំងពីឆ្នាំ១៩៣៩ ហើយឆ្លុះបញ្ចាំងពីជីវិតនៃការត្រិះរិះ (ជាបញ្ញវន្ត) ពេញមួយជំនាន់។ គាត់ក៏ជាអ្នកនិពន្ធរឿង *Retour de l'U.R.S.S.* ឆ្នាំ១៩៣៦។ គាត់បានទទួលរង្វាន់ណូបែលអក្សរសាស្ត្រ នៅឆ្នាំ១៩៤៧[១៣]។ រឿងប្រិយនារី របស់វ៉ូដ្វាយ៉េ (*LA BIEN aimée de Vandoer*) រឿងម៉ាតាហារី និយាយពីនាងម៉ាតាហារី កើតនៅឆ្នាំ១៨៧៦ ស្លាប់ក្នុងឆ្នាំ១៩១៧ ជាស្រីរបាំជាតិហោអង់ដេស៍ ល្បីល្បាញដោយការសម្តែងក្បាច់រាំឥណ្ឌូនេស៊ី។ នាងត្រូវគេបាញ់សម្លាប់នៅប្រទេសបារាំង ក្នុងនាមជាចារកិច្ចដើម្បីផលប្រយោជន៍ឱ្យអាល្លឺម៉ង់ ក្នុងសង្គ្រាមលោកលើកទី១[១៤]។ ប្រភពទាំងអស់នេះអាចបង្ហាញថា អ្នកនិពន្ធ នូ ហាច មិនត្រឹមតែបានទទួលឥទ្ធិពលក្នុងការតែងនិពន្ធពីសាស្ត្រាល្បែងបែបបុរាណដែលនាំឱ្យលោកចេះរបៀបពិពណ៌នា រៀបរាប់ទេសភាពបានយ៉ាងល្អប៉ុណ្ណោះទេ តែលោកក៏បានទទួលផងដែរពីអក្សរសិល្ប៍បស្ចឹមប្រទេស ពិសេសប្រលោមលោកបារាំងលើការអភិវឌ្ឍន៍ផ្នែកចិត្តគំនិត ការគិតគូរ ពិចារណាផ្សេងៗ ក្នុងជីវភាពរស់នៅ ក្នុងសង្គមការងារ ជាពិសេសលើបញ្ហាស្នេហា។

## ៤- និន្នាការរបស់អ្នកនិពន្ធ

ដោយសារតាមរយៈឥទ្ធិពលទាំងឡាយ ដែលអ្នកនិពន្ធទទួលបាន ទាំងឥទ្ធិពលពីអក្សរសិល្ប៍បស្ចឹមប្រទេសផងនោះ ទើបគេអាចមើលឃើញតាមរយៈស្នាដៃនិពន្ធ លោក នូ ហាច បានបង្ហាញពីផ្នត់គំនិតថ្មីលើរចនាបថ វិធីសាស្ត្រតែងនិពន្ធ ខ្លឹមសារនៃរឿង និងតម្លៃនៃរឿងដែលមានទំនោរទៅរកភាពទំនើបជឿនលឿន មានលក្ខណៈមនុស្សនិយម តថនិយម បម្រើឱ្យផលប្រយោជន៍មនុស្សទូទៅ។ ការលើកយក «ស្នេហា» ធ្វើជាប្រធានបទក្នុងរឿងផ្កាស្រពោនរបស់អ្នកនិពន្ធ នូ ហាច រួមជាមួយស្នាដៃរឿងកូលាបប៉ៃលិន រឿងបិសាចស្នេហា របស់អ្នកនិពន្ធ ញ៉ុក ថែម រឿងសុផាត របស់អ្នកនិពន្ធ រីម គីន រឿងទឹកទន្លេសាប របស់អ្នកនិពន្ធ គីម ហាក់ ជាដើមនោះបានបង្កីតការវិវឌ្ឍន៍ថ្មីមួយ គឺការបើកទំព័រនៃការចាប់ផ្តើមរបស់អក្សរសិល្ប៍ប្រលោមលោកពាក្យរាយខ្មែរ នាយុគសម័យថ្មីដែលដោះស្រាយបញ្ហាជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សទូទៅ លែងវិលទៅរកអច្ឆរិយ ភាពការស្រមើស្រម៉ៃការសណ្តំព្រលឹងវិញ្ញាញដែលទន់ខ្សោយអស់សង្ឃឹមដោយការនឿយណាយនឹងសង្គ្រាម ការចាញ់សង្គ្រាមជាញឹកញាប់ចាប់ពីក្រោយសម័យអង្គរជាច្រើនសតវត្ស ឱ្យមានក្តីសង្ឃឹមថា ថ្ងៃណាមួយនឹងចាកផុតទុក្ខទាំងឡាយ ដោយសារតួអង្គអច្ឆរិយៈណាមួយមកជួយប្រោសព្រំតាមរយៈសាស្ត្រាល្បែង។

ក្នុងការបកស្រាយពីបញ្ហាជីវភាពរស់នៅក្នុងរឿងផ្កាស្រពោន លោក នូ ហាច បានបង្ហាញអោយយើងឃើញនូវលក្ខណៈខុសឆ្គងទាំងក្នុងនិន្នាការ ទាំងក្នុងជីវភាពសង្គមខ្មែរ ដែលអាចចាត់ទុកថា ជាបុព្វហេតុសំខាន់ក្នុងវិបត្តិស្នេហាយុវជន។ តាមដំណើររឿងយើងសង្កេតឃើញថា អ្នកនិពន្ធហាក់ដូចជាសង្កត់ធ្ងន់លើនិន្នាការពីរ៖ គឺការនិយមទ្រព្យសម្បត្តិ និងការនិយមបំបិទសិទ្ធិសេរីភាពយុវជនក្នុងការជ្រើសរើសគូស្រករ។ ដោយសារនិន្នាការ

---

[១៣]. Voir GEORGES PASCAL ***NOUVELLE ENCYCLOPEDIE BORDAS IV*** compression / Europe, 1985, p. 2210.

[១៤]. Voir GEORGES PASCAL ***NOUVELLE ENCYCLOPEDIE BORDAS VI*** compression / Europe, 1985, p.3287.

ទាំងពីរនេះ តួអង្គទាំងអស់ហាក់ដូចជាមានគុណវិបត្តិ ដែលសុទ្ធសឹងជាមូលហេតុកំណត់វាសនាអាក្រក់ដល់នាងវិជារី [១៥]។

វិវឌ្ឍពីបញ្ហាស្នេហា និងការរក្សាកិត្តិយសរបស់តួអង្គ ប៊ុន ធឿន ក្នុងរឿងផ្កាស្រពោន ទៅជា ឧត្តមគតិស្នេហាជាតិដែលស្តែងចេញតាមរយៈតួអង្គ ទីឃាវុធ ក្នុងរឿងមាលាដួងចិត្ត បានបង្ហាញពីនិន្នាការជាតិនិយមដ៏ជ្រាលជ្រៅរបស់អ្នកនិពន្ធ នូ ហាច ដែលគេមិនបានឃើញក្នុងស្នាដៃនិពន្ធនៃអ្នកនិពន្ធដទៃទៀត ដែលពោរពេញទៅដោយគំនិតសន្តិភាពនិយម ការផ្សះផ្សាប្រជាជាតិពីរជ្រែកក្រោមម្លប់ព្រះពុទ្ធសាសនាតែមួយ ក្រោមរូបភាពស្នេហា។ ប្រឈមមុខនឹងសេចក្តីស្នេហាដ៏ជ្រាលជ្រៅ ដែលខ្លួនមានចំពោះនារីសៀមម្នាក់នេះ (នាងចន្ទមណី) ទីឃាវុធបានធ្វើការសម្រេចចិត្តមួយ ដែលមានទម្ងន់រវាងផលប្រយោជន៍ក្នុងរឿងស្នេហាផ្ទាល់ខ្លួន និងអធិបតេយ្យភាពបូរណភាពទឹកដី កិត្តិយសជាតិដែលត្រូវជាតិសាសន៍របស់នាង (សៀម) ប្រមាថមើលងាយ ធ្វើការឈ្លានពានដោយប្រើកម្លាំងទ័ពលុកលុយយ៉ាងគគ្រឹក ក្នុងបំណងលេបត្របាក់យកទឹកដីភាគពាយ័ព្យនៃប្រទេសខ្មែរ។ ទោះបីសង្គ្រាមបានចប់ទៅហើយក្តី ទោះបីដឹងថាព័ត៌មានដែលមិត្តអ្នកផ្តល់មកនោះជាការយល់ច្រឡំក្តី ទីឃាវុធ មិនបានសូម្បីតែមានបំណងបំភ្លេចពាក្យសម្បថចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូបនៅអង្គរ ដែលបង្ហាញពីទឹកចិត្តជាតិនិយម របស់គេឡើយ។

ក្រៅពីនេះ អ្នកនិពន្ធបានបង្ហាញពីសម្រស់ទេសភាពធម្មជាតិ ទឹកដី ព្រៃព្រឹក្សាដែលជានិន្នាការសំខាន់មួយដែរ សម្រាប់លម្អផ្ទៃរឿងក្នុងវិធីតំណែងនិពន្ធរបស់អ្នកនិពន្ធសម័យមុន។

## ៥- ឧត្តមគតិរបស់អ្នកនិពន្ធ

លោក នូ ហាច ជាអ្នកនិពន្ធរឿងប្រលោមលោកបែបមនោសញ្ចេតនាមួយរូប ដែលមានទឹកដៃ ប្រកបដោយទេពកោសល្យក្នុងការតែងនិពន្ធ។ ប្រធានបទសំខាន់នៅក្នុងស្នាដៃរបស់លោកគឺ រឿងស្នេហា (សេចក្តីស្នេហារបស់យុវវ័យ និងឧត្តមគតិស្នេហាជាតិ)។

នៅក្នុងរឿងផ្កាស្រពោន អ្នកនិពន្ធបានឱ្យតម្លៃខ្ពស់ទៅលើការកសាងសុភមង្គលគ្រួសារដោយពឹងផ្អែក ទៅលើចំណេះដឹង និងការចេះយល់ចិត្តថ្លើមគ្នារបស់គូស្រករ។ ក្នុងការចាត់ចែងគូស្រករកូនចៅ អ្នកនិពន្ធមិនឱ្យតម្លៃទៅលើទ្រព្យសម្បត្តិតែម្យ៉ាងថាអាច ផ្តល់សេចក្តីសុខដល់គូស្រករដែលនឹងចាប់ដៃគ្នាកសាងគ្រួសារថ្មីមួយនោះទេ។ តាមរយៈយាយនួន បង្ហាញឱ្យឃើញថា ការប្រកាន់ឥរិយាបថរឹងត្អឹង ចូលចិត្តកៀបសង្កត់កូនចៅឱ្យធ្វើតម្រូវតាមចិត្តខ្លួនជាចាស់ទុំ នោះមិនមែនសុទ្ធតែត្រូវគ្រប់ពេលនោះទេ។ ការបំបិទសិទ្ធិសេរីភាពកូនចៅ ក្នុងការជ្រើសរើសគូស្រករ ជាប្រការមួយគួរត្រូវជៀសវាង ព្រោះការធ្វើបែបនេះ មិនបាននាំអ្វីជាផលល្អដល់អ្នកជាមាតាបិតាអាណាព្យាបាល ឬបុត្រធីតាឡើយ លទ្ធផលបានត្រឹមតែភាពសោកាដូចជាយាយនួន ជាម្តាយនាងវិជារី តែប៉ុណ្ណោះ។

អ្នកនិពន្ធ នូ ហាច ផ្តល់បទពិសោធន៍ជាច្រើនក្នុងរឿងស្នេហាតាមរយៈនាងវិជារី ប៊ុន ធឿន។ ភក្តីភាពជាកត្តាសំខាន់ក្នុងការកសាងសុភមង្គលគ្រួសារ។ រឿងនេះអ្នកនិពន្ធឱ្យតម្លៃជាខ្លាំងលើស្នេហា ធ្វើឱ្យស្នេហាមាន

---

[១៥]. សោម សុមុនី *អក្សរសិល្ប៍ពាក្យរាយខ្មែរ* ជ.ឯ.ម ទំព័រ១១៥។

ឥទ្ធិពលគ្របដណ្ដប់លើការស្លាប់រស់របស់នារីខ្មែរតាមរយៈនាងវិធាវី។ តាមរយៈតួអង្គ នាងវិធាវី អ្នកនិពន្ធចង់បណ្ដុះទឹកចិត្តស្មោះស្ម័គ្រភក្ដីចំពោះស្នេហាដល់យុវជនទាំងឡាយ ដែលទោះបីជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយនាងនៅតែប្រកាន់ខ្ជាប់ភក្ដីភាពចំពោះគូស្នេហ៍ មិនងាករេឡើយ។

នាងវិធាវី ជាគំរូមួយយ៉ាងល្អក្នុងការប្រកាន់ឥរិយាបថល្អ ទន់ភ្លន់ សុភាពរាបសារ ស្រគត់ស្រគំ ស្ដាប់បង្គាប់អ្នកមានគុណ ពិសេសភក្ដីភាពចំពោះស្នេហា។ ថ្វីត្បិតតែនាងមិនបានទទួលផលតបស្នងយ៉ាងប្រពៃមួយឱ្យសមទៅនឹងតម្លៃនៃការប្រព្រឹត្តរបស់នាងក៏ពិតមែន ប៉ុន្តែសង្គមខ្មែរបានឱ្យតម្លៃនាងយ៉ាងខ្លាំង នាងជានារីគំរូមួយរូបសម្រាប់សុភាពស្ត្រីទាំងឡាយប្រតិបត្តិតាមទង្វើល្អៗទាំងនោះ។

ចរិតរមទម្យពេក អៀនអន់ពេករបស់នារីមួយចំនួនដូចជានាងវិធាវី ជាកិរិយាមួយដែលគួរលះបង់ចោល ព្រោះការប្រកាន់យកឥរិយាបថទាំងនេះមិនបានជួយអ្វីដល់នាងឡើយ វាបានត្រឹមតែនាំមកនូវក្ដីទុក្ខសោកាដល់អ្នកប្រព្រឹត្តតែប៉ណ្ណោះ។

ការសិក្សា ជាមធ្យោបាយមួយដ៏ល្អសម្រាប់យុវជនគ្រប់រូបក្នុងការរៀបចំ កសាងអនាគតរបស់ខ្លួនឱ្យប្រព្រឹត្តទៅបានល្អ ប្រកបដោយសុភមង្គល។

ការងប់ងល់តែលើការសិក្សាមួយមុខ ហើយមិនទទួលខុសត្រូវ មិនហ៊ានប្រឈមមុខនឹងការពិតចំពោះមុខក្នុងរឿងស្នេហា តាមរយៈ ប៊ុន ធឿន ត្រូវទទួលលទ្ធផលមួយគឺការព្រាត់ប្រាស់ពីគូស្នេហ៍ ដែលខ្លួនប្រាថ្នាជាគូអនាគត។

អ្នកនិពន្ធ នូ ហាច បានបណ្ដុះនូវទឹកចិត្តស្នេហាជាតិដ៏ឧត្ដុង្គឧត្ដមចំពោះបណ្ដាអ្នកអានគ្រប់មជ្ឈដ្ឋាន ពិសេសស្រទាប់យុវជនខ្មែរដែលជាសសរទ្រូងដ៏រឹងមាំក្នុងបុព្វហេតុការពារ និងអភិវឌ្ឍន៍ជាតិមាតុភូមិ ទប់ទល់នឹងខ្មាំងសត្រូវគ្រប់ប្រភេទ (នឹមអាណានិគម ការរំលោភឈ្លានពានរបស់ប្រទេស ដែលមានព្រំប្រទល់ជាប់គ្នា ភាពឱនថយលើគ្រប់វិស័យរបស់ជាតិ...) គំនិតសន្តិភាពនិយម ការផ្សះផ្សាប្រជាជាតិដែលនៅជិតខាងគ្នាមានទំនាស់គ្នាក្រោមម្លប់ដ៏ត្រជាក់នៃព្រះពុទ្ធសាសនា តាមរយៈរឿងមាលាដួងចិត្ត។ រឿងមាលាដួងចិត្ត បង្ហាញឱ្យអ្នកអាន ឃើញពីស្ថានភាពសង្គមខ្មែរនាសម័យអាណាព្យាបាល បារាំងដែលពោរពេញទៅដោយមន្ត្រីពុករលួយ អសមត្ថភាពការងារ រួមដៃជាមួយឈ្មួញ កេងប្រវ័ញ្ចផល ប្រយោជន៍ជាតិបំពេញមហិច្ឆតាផ្ទាល់ខ្លួន ការបណ្ដុះនូវគំនិតមនសិការការងារ ស្អប់ខ្ពើមអំពើពុករលួយ អសកម្មការងារ តាមរយៈតួអង្គ ទីឃាវុធ ប្រាមោទ វេគី។

ការបណ្ដុះឧត្ដមគតិស្នេហាជាតិ ការបេះថ្លឹងថ្លែងរវាងផលប្រយោជន៍ជាតិ និងផលប្រយោជន៍បុគ្គលតាមរយៈតួអង្គ ទីឃាវុធ ដែលស៊ូលះបង់ស្នេហាដើម្បីបូរណភាពទឹកដី «យើងជួបមុខគ្នាពេលនេះ ប្រហែលជាលើកក្រោយបំផុតហើយ ព្រោះបងបានទៅសច្ចាប្រណិធានចំពោះព្រះភក្ត្រព្រះពុទ្ធរូបនៅអង្គរវត្តថាដរាបណា ខេត្តខ្មែរដីខ្មែរដែលបានទៅសៀម ក្នុងពេលថ្មីៗនេះមិនត្រឡប់មកខ្មែរវិញទេ ដរាបនោះ បងប្ដូរផ្ដាច់មិនព្រមយកសៀមជាមិត្ត ជាក្លើជាម្រាក់អ្វីឡើយ»។

រឿងនេះក៏បានបង្ហាញផងដែរពីការបណ្ដុះគំនិតសន្តិភាពនិយមរបស់អ្នកនិពន្ធ ចូលចិត្តរស់នៅក្នុងសុខសន្តិភាព ភាតរភាពរវាងគ្នា និងគ្នា មិនចូលចិត្តសង្គ្រាមឈ្លានពាន ការរំលោភបំពានទៅលើអធិបតេយ្យភាពបូរណភាពទឹកដីប្រទេសដទៃ។ គំនិតនេះស្ដែងឡើងតាមរយៈសំបុត្រដែលវេគីផ្ញើឱ្យទីឃាវុធ «ដូចឯងបានស្ដាប់ឮតាមវិទ្យុ ឬអានដឹងក្នុងកាសែតស្រាប់ហើយ ប្រទេសសៀមកំពុងឆ្លៀតឱកាសក្នុងបារាំងអន្ទការ ដើម្បីវាត

អាណាចក្រ រំលោភមកលើដែនដីខ្មែរនិងឡាវ។ មិនគួរធ្វើយ៉ាងនេះសោះ ! ប្រទេសដែលយើងទុកជារៀមច្បង បែរជាចង់ត្របាក់ប្អូនៗតូចៗ មើលតែត្រីឆ្តោរតែម្តង»។

បញ្ហាកិត្តិយសក៏ជារឿងសំខាន់មួយដែលអ្នកនិពន្ធលើកយកមកបង្ហាញតាមរយៈតួអង្គ ប៊ុនធឿន និង ទីឃាវុធ ផងដែរ។ តាមរយៈសកម្មភាពរបស់តួអង្គទាំងពីរ គេអាចមើលឃើញថាអ្នកទាំងពីរសុទ្ធតែជាមនុស្សត្រូវការកិត្តិយស មិនចង់ឱ្យមានអ្នកណាម្នាក់ ឬច្រើនប្រមាថមើលស្រាលដល់គេឡើយ។ ប៊ុន ធឿន សុខចិត្តលះបង់នារីជាទីស្រឡាញ់ដោយមិនចង់មានបញ្ហារឿងទ្រព្យសម្បត្តិ ពាក្យដំណៀលផ្សេងៗ។ ការសម្រេចចិត្តក្នុងរឿងស្នេហារបស់តួអង្គ ប៊ុនធឿន ជាការសម្រេចចិត្រដែលប្រកបដោយការគិតគូរពិចារណា ថ្លឹងថ្លែងរវាងស្នេហា និង កិត្តិយស «ការប្រព្រឹត្តដូច ប៊ុនធឿន ជាការប្រសើរវិសេសណាស់ ទោះជាចោទថា ប៊ុនធឿន មិនអាចហ៊ានធ្វើអន្តរាគមន៍អ្វីលើរឿងនេះក៏ដោយ ក៏ជាការផ្ទុយស្រឡះដែរ ព្រោះយើងអាចមើលឃើញថា ប៊ុនធឿន បានរក្សានឹងស្រឡាញ់កិត្តិយសជាងស្រឡាញ់អ្វីៗទាំងអស់។ គំនិតម្យ៉ាងដែលយុវជនបានផ្តងឡើង គឺការអេស់ចំណង់ ដែលមានបញ្ហាជុំវិញខ្លួនបានចោទឡើងជាប្រធាន។ បរិយាកាសជុំវិញខ្លួននោះមានច្រើនយ៉ាងណាស់ គឺទី១អ្នក នឹកឃើញថា យាយនួន កាលដើមឡើយស្រឡាញ់អ្នកនិងគ្រួសារអ្នកណាស់ ក៏ប៉ុន្តែក្នុងកាលនោះមាតាបិតាអ្នកនៅមានទ្រព្យពេញផ្ទះគ្រប់គ្រាន់ចាយនៅឡើយ លុះទ្រព្យរលាយ យាយនួនក៏ដកចិត្តដែរ។ ដូច្នេះការស្រឡាញ់កាលពីមុនក៏ដោយសារមានទ្រព្យជាគ្រឿងផ្សំផង។ ទី២ ការយកបាតដៃធ្វើជាខ្នងដៃយ៉ាងឆាប់រហ័សនេះជាអំពើ១ គួរឱ្យស្អប់បំផុត ហើយរូបអ្នកក្តី អ្នកឯទៀតក្តីគប្បីតែជៀសវាងឱ្យឆ្ងាយអំពីជនជំពូកនេះ។ ទីបីកាល បើអ្នកចូលធ្វើអន្តរាគមន៍ហើយបានរូបនាងវិធាវី ជានារីគួរឱ្យស្រឡាញ់មកធ្វើជាគូជីវិតហើយ ក៏មិនជាការវិសេសវិសាលឡើយ ព្រោះមាតាបិតានាងគ្មានការពេញចិត្តចំពោះអ្នក។ ចុះបើគ្រាក្រោយ មានវិបត្តិខាងទ្រព្យសម្បត្តិធ្លាក់មកត្រូវធ្ងន់ជាងនេះទៅទៀត តើយ៉ាងណាទៅវិញ អើគួរឱ្យធុញទ្រាន់នឹងរស់នៅជាមួយណាស់ ព្រោះមនុស្សណាក៏ដោយឱ្យតែយកទ្រព្យធ្វើជាឈ្នាន់ សម្រាប់ឡើងទៅកាន់ភាពសុខដុមរមនានឹងគ្នាហើយ មនុស្សនោះនឹងយកធ្វើជាញាតិមិត្តពុំបានឡើយ ព្រោះកាលណាគ្មានទ្រព្យ មុខជាត្រូវវេទនាខាងផ្លូវចិត្តសម្បើម។ អាស្រ័យហេតុនេះ បានជា ប៊ុនធឿន ត្រូវដើរគេចចេញឱ្យហើយៗបែរទៅប្រព្រឹត្តធ្វើអាកប្បកិរិយានឹងនទៅវិញ មិនតែប៉ណ្ណោះសោតការធ្វើយ៉ាងនេះ ក៏ជាមធ្យោបាយ ១ នាំឱ្យមានសុខស្រួលរវាងខ្លួន និងជនជាសត្រូវផង នាំឱ្យកិត្តិយសអនាគតរបស់ខ្លួនមានរស្មីល្អផង»។

ទីឃាវុធ មានការសេចក្តីក្រេវ ក្រោធពេលដែលដឹងថាខ្លួនចាញ់បោកគេតាមរយៈ វេគី ជាមិត្តជិតដិតនិងជាសមាជិកក្រុមសម្ងាត់។ ការចាញ់ឧបាយគេនេះ គឺចាញ់យ៉ាងធ្ងន់សម្រាប់រូបគេ ចាញ់ដោយសារចាញ់ចិត្តលង់ស្នេហ៍គេ ចាញ់ដោយសារគេបំពានលើសេចក្តីទុកចិត្តរបស់ខ្លួន ពិសេសគឺចាញ់ដោយសារគេយកសេចក្តីស្នេហាបរិសុទ្ធរបស់ខ្លួនមកជាន់ឈ្លី បម្រើឱ្យប្រយោជន៍នយោបាយចារកម្ម ធ្វើឱ្យស្រុកទេសខ្លួនមានវិបត្តិត្រូវគេប្រមាថឈ្លានពានយ៉ាងកម្រោល «ស្រី ចង្រៃ... ស្រីកាំឡកិណ្ណី... ស្រីថ្លើមខ្មៅ... យ៉ាងនោះមែនឬអី ? ចិត្តឆ្លើយភ្លាមថាពុំមែនទេ ! ពុំមែនទេ ត្បិតអី កិរិយានាងទន់ភ្លន់យ៉ាងនេះ សេចក្តីស្មោះត្រង់យ៉ាងនេះ មិនសមនឹងមានគំនិតអាក្រក់លាក់លៀមបានឡើយ។ ឯឪពុកសោតក៏គួរសំគាល់បានថា ជាមនុស្សមានចិត្តធម៌ ចិត្តកក្តីឥតវៀចវេរបានទេ។ ទីឃាវុធ អន្ទះអន្ទែង វិលវល់ក្នុងសេចក្តីសង្ស័យហើយបំរុះឯកាក្នុងគ្រែមួយ ដែលមានសភាពហាក់ដូចជាក្រាលនូវបន្លាដែលចាក់ សាច់មុតពេញខ្លួន រកផ្អៀងទៅខាងណាក៏ពុំផុតរំខានឡើយ។ ដោយធ្លាប់អានសៀវភៅ និងមើលកុន ហើយនឹកដល់រឿងម៉ាតាហារី ក្នុងសង្គ្រាមលោកលើកទី១ បាល័ដ្ឋកម្លោះក៏មានអារម្មណ៍មួយប្លែក។ គេថា

ពួកចោរបុរស ឬចោរនារីប្រសប់លាក់គំនិតណាស់ ក្លែងធ្វើឬកពារឱ្យឯងភ្លេចខ្លួន។ អីចឹងមែនហើយហ្ន៎ ! នាងចោរនារី ចន្ទមណី ជាបុត្រីចោរបុរស ទេពកោសល្ល វិចិត្រករ។

ក្រុមសម្ងាត់ធ្វើការម៉ត់ចត់ល្អណាស់ មិនងាយចោទព្រាវៗកើតទេ។ មួយទៀត វេគី គឺជាមិត្តស្និទ្ធិស្នាល របស់ខ្លួន មានការស្ទាត់កំបាំងយ៉ាងណា ពុំដែលលាក់លៀមនឹងគ្នាទេ។ ឯទីឃាវុធ ធ្លាប់បាននិយាយប្រាប់សម្លាញ់ថា ខ្លួនចាប់គួចស្នេហានាងចន្ទមណី។ ទាល់តែច្បាស់ការពិតប្រាកដណាស់ហើយ ទើបហ៊ានមករំលាយបេតីដ៏ធំទូលាយរបស់ខ្លួន។ ពិតជាក្រុមចោរកម្មទាំងឪពុកទាំងកូនមែនហើយ ទើបឥឡូវលែងឱ្យដំណឹងមកសោះ។ ខ្លួនអើយខំស្រឡាញ់គេបង់ចិត្ត ! ឥឡូវគប្បីរកវិធីកែខ្លួន សងសឹកសេចក្ដីស្នេហាថ្លាបរិសុទ្ធ ដែលមានមនុស្សពាលយកមកឈ្លីលេងជាល្បែង»។ គេស្ដាយក្រោយចំពោះការភ័ន្តច្រឡំរបស់ខ្លួនលើនាងចន្ទមណី ធ្វើឱ្យគេក្លាយជាមនុស្សរមើលគុណ «ឯងនិយាយនោះត្រូវហើយ។ ខ្ញុំបានទៅស្បថអង្គរស្រេចថាបើមិនបានបាត់ជំបងមកវិញទេ ខ្ញុំក៏មិនខ្វីទាក់ចិត្តរាប់រកសៀមណាថាជាភ្លើម្រាក់ជាមិត្តភក្ដិ ឬជាអ្វីទៀតទាំងអស់។ ប៉ុន្តែមកទាស់ស្ដាយបន្តិច ព្រោះការភ័ន្តច្រឡំរបស់ឯង បានបណ្ដាលឱ្យខ្ញុំប្រព្រឹត្តអាកប្បកិរិយាមិនគប្បីតបនឹងសេចក្ដីគួរសម នឹងការយកចិត្តទុកដាក់របស់គេ។ មិនគួរសោះ ! មិនគួរសោះ ! នេះជាពាក្យបន្ទោសខ្លួនឯងក្នុងពេលកំពុងដើរត្រួតគុម្ពផ្កា។ មិនគួរសោះ ! ស្ដាយណាស់ មិនគប្បីសោះឱ្យជាតិដទៃមកមើលងាយខ្លួនបានថាជាមនុស្សពាលមនុស្សជួរមើលគុណគេ»។

## ៦- ប្រវត្តិការងារ

ក្រោយបញ្ចប់ការសិក្សា លោក នូ ហាច បានបំពេញការងារជាច្រើនក្នុងរាជការខ្មែរនាសម័យនោះដោយពេលខ្លះលោកកាន់កាប់តំណែងតួនាទីធំដុំជាសមាជិករាជរដ្ឋាភិបាល ជាមន្ត្រីការទូតជាន់ខ្ពស់ទៀតផង។ ចាប់តាំងពីពេលចូលបម្រើការងាររហូតដល់វ័យចូលនិវត្តន៍ លោកជាមន្ត្រីបួនជំនាន់ក្នុងរាជការខ្មែរសម័យនោះ គឺសម័យអាណាព្យាបាលបារាំង សម័យឯករាជ្យ សម័យសង្គមរាស្ត្រនិយម និងសម័យសាធារណរដ្ឋខ្មែរ។ ប្រវត្តិការងាររបស់លោកដែលគេអាចរកឃើញ ជាអាទិ៍ ៖

ឆ្នាំ១៩៣២ បានប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យស៊ីសុវត្ថិ រហូតដល់ឆ្នាំ១៩៣៩ ក្រោយដែលបានជាប់មធ្យមសិក្សាប័ត្រភាគទីមួយហើយ លោកបានចូលធ្វើជាចៅក្រម ផ្លាស់មកភ្នំពេញវិញ ក្រោយរៀបអាពាហ៍ពិពាហ៍។

ឆ្នាំ១៩៤៧ បានទៅបម្រើនៅក្រសួងឃោសនាការ កាន់កាប់ខាងការផ្សាយផ្សាយកាសែតកម្ពុជា។

ឆ្នាំ១៩៤៨ ធ្វើជាលេខាផ្ទាល់នៃទ្រង់យុត្តិវង្ស នាយករដ្ឋមន្ត្រី បន្ទាប់ពីទ្រង់យុត្តិវង្សសុគតទៅ លោកត្រឡប់មកក្រសួងឃោសនាការវិញ ធ្វើជានាយខុទ្ទកាល័យ។

ឆ្នាំ១៩៥២ លោកចូលទៅបម្រើនៅក្រសួងការបរទេសវិញ ដែលមានមុខងារជាមន្ត្រីការទូតខ្មែរ។

ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥២ ដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៥៣ សម្ដេចព្រះ នរោត្តម សីហនុ ជានាយករដ្ឋមន្ត្រី បានតែងតាំងលោក នូ ហាច ជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍ ដោយក្រឹត្យលេខ ២៥២ ថ្ងៃ១៥ ខែមិថុនា ឆ្នាំ១៩៥២។

លោក នូ ហាច បានចូលជាសមាជិកនៃសមាគមអ្នកនិពន្ធខ្មែរតាំងពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៥៨។

ក្នុងក្រសួងការបរទេស លោកបានទទួលមុខតំណែងចុងក្រោយបង្អស់ជាឯកអគ្គរាជទូតខ្មែរ ប្រចាំនៅប្រទេសឥណ្ឌូនេស៊ី ប្រហែលនៅឆ្នាំ១៩៦៥។ លោកចូលនិវត្តន៍ ចូលភ្នំពេញ ប្រហែលមុនឆ្នាំ១៩៧៥ [១៦]។

ឯកសារមួយផ្សេងបញ្ជាក់ថា ក្នុងគស១៩៤៨ លោកបានចូលទៅធ្វើជាសុភាចារបុរសនៅសាលាដំបូងខេត្តសៀមរាប។ ក្រោយមក ក្រសួងយុត្តិធម៌បានផ្លាស់លោកឱ្យមកធ្វើការនៅសាលាឧទ្ធរណ៍។ លោកបាន ធ្វើជានាយកាប៊ីណេត៍ ក្រសួងឃោសនាការជាតិ ក្នុងគ.ស.១៩៤០។ ក្នុងឆ្នាំ១៩៥២ លោកធ្វើជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍។ លោកធ្លាប់ធ្វើជានាយការិយាល័យនៅក្រសួងសេដ្ឋកិច្ចជាតិ បន្ទាប់មកធ្វើជា នាយការិយាល័យវប្បធម៌ និងសេដ្ឋកិច្ច នៅក្រសួងការបរទេស។ លុះមកដល់ឆ្នាំ១៩៥៥៣ លោកនូ ហាច បានធ្វើជាទីប្រឹក្សាស្ថានអគ្គរាជទូតប្រទេសកម្ពុជា ប្រចាំប្រទេសថៃរហូតសព្វថ្ងៃនេះ[១៧]។

ក្នុងឋានៈជាទីប្រឹក្សានៅស្ថានឯកអគ្គរាជទូតប្រទេសកម្ពុជានាក្រុងបាងកក រាជកាបានចាត់តាំងលោក នូ ហាច ជាតំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេនាក្រុងបាងកក។ ជាមួយគ្នានេះ រាជការបានចាត់តាំង លោក នូ ហាច ឱ្យបំពេញបេសកកម្មជាប្រតិភូតំណាងប្រទេសកម្ពុជា ជាច្រើនលើកក្នុងសន្និបាតថ្នាក់តំបន់មួយចំនួន ដូចជា រាជក្រឹត្យលេខ៦៨៥-ប.វ. ចុះថ្ងៃទី២៤ ខែធ្នូ គ.ស.១៩៦០ បានចាត់តាំងភ្នាក់ងាររាជការមួយក្រុមជាតំណាងប្រទេសកម្ពុជានៅក្នុងសន្និបាតលើកទី៨ នៃគណៈកម្មាធិការដឹកនាំខាងក្នុងនិងគមនាគមន៍ ដែលមានធ្វើនៅក្រុងបាងកក ពីថ្ងៃ១៨ ដល់ថ្ងៃ២៤ វិច្ឆិកា គ.ស.១៩៦០ ដោយមានលោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការ អេកាហ្វេ នាក្រុងបាងកក ជាប្រធាន និងលោក ឈុត ឈឿ វិស្វករនៃសាធារណៈការ ជាសមាជិក[១៨]។ រាជក្រឹត្យលេខ៥៣៥-ប.វ. ចុះថ្ងៃទី៩ តុលា គ.ស.១៩៦១ បានចាត់ភ្នាក់ងាររាជការមួយក្រុមជាតំណាងប្រទេសកម្ពុជា នៅកិច្ចចរចាអំពីវឌ្ឍនភាពនៃពាណិជ្ជកម្មសម្រាប់ភូមិភាគនឹងនៅសន្និបាតលើកទី៣ នៃគណៈកម្មាធិការខាងពាណិជ្ជកម្មនៅក្រុងបាងកក ក្នុងដើមខែមករា ឆ្នាំ១៩៦០ ដោយមានលោក នូ ហាច ទីប្រឹក្សានៅស្ថានឯកអគ្គរាជទូតប្រទេសកម្ពុជា នាក្រុងបាងកក ជាប្រធាន និងលោក អ៊ុង ប៊ុនហោ លោក អ៊ុង បូយគ័ន លោក លឹម សុភាព ជាសមាជិក[១៩]។ រាជក្រឹត្យលេខ៥៣៧-ប.វ. ចុះថ្ងៃទី៩ តុលា គ.ស.១៩៦១ បានចាត់ភ្នាក់ងាររាជការមួយក្រុមជាតំណាងប្រទេសកម្ពុជា នៅសន្និបាតលើកទី១៦ នៃអង្គការអេកាហ្វេ ដែលមានធ្វើនៅក្រុងបាងកក ពីថ្ងៃ៩ ដល់ថ្ងៃ២១ មីនា គ.ស.១៩៦០ ដោយមានលោក សុន វីនសៃ ទីប្រឹក្សាជំនាញនៅក្រសួងផែនការ ជាប្រធាន លោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេនាក្រុងបាងកក លោក កែ ណុល លោក ប៉េង ប៉ុន ជាសមាជិក[២០]។ រាជក្រឹត្យលេខ៥៤១-ប.វ. ចុះថ្ងៃទី៩ តុលា គ.ស.១៩៦១ បានចាត់ភ្នាក់ងាររាជការមួយក្រុម ជាតំណាង ប្រទេសកម្ពុជានៅសន្និសីទលើកទី៣

---

[១៦]. សូមមើល នូ ហាច *មាលាដួងចិត្ត* ដ.ឯ.ម ទ៓ព័រ ក-ខ-គ។

[១៧]. គឹម សែត ដéម ទំព័រ២៥៥ ២៥៦។

[១៨]. សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ៥ ទំព័រ១៧៦។

[១៩]. សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២៣០ ថ្ងៃព្រហស្បត៏ ទី១៩ តុលា គស១៩៦១ ទំព័រ៧៧០៣។

[២០]. សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២៣០ ដéម ទំព័រ៧៧០៤។

ខាងស្ថិតិលេខកៈ នៃអាស៊ីដែលធ្វើនៅក្រុងបាងកក ពីថ្ងៃទី៥ ដល់ថ្ងៃ ទី១៥ មេសា គ.ស.១៩៦០ ដោយមានលោក សរ គិមតួយ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន លោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេនាក្រុងបាងកក,លោក ស៊ីន សាមុត, លោក សៅ ខាន់ ជាសមាជិក[២១]។ ព្រះរាជក្រឹត្យលេខ៨១២-ប.រ. ចុះថ្ងៃទី១៥ កញ្ញា គ.ស.១៩៦១ បានចាត់អ្នករាជការមួយក្រុមជាតំណាងប្រទេសកម្ពុជា នៅសន្និបាតលើកទី១ ស្តីអំពីមណ្ឌលនៃវិធីអន្តរជាតិ ប្រារព្ធនៅក្រុងបាងកក ពីថ្ងៃ១៩ ដល់ថ្ងៃ២១ វិច្ឆិកា គ.ស.១៩៥៩ ដែលមានលោក នូ ហាច តំណាងអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា នៅអមអង្គការអេកាហ្វេនាក្រុងបាងកកជាប្រធាន និងលោក ឈុត ឈឿ ជាសមាជិក[២២]។

ក្រឹត្យលេខ២៥២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ តែងតាំងលោក នូ ហាច ជាសមាជិករាជរដ្ឋាភិបាលមានឋានៈជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍ ត្រូវបានជំនួសបញ្ជាក់ជាថ្មីដោយក្រឹត្យលេខ២៥៤ N-S ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៥២[២៣]។

ក្នុងឋានៈជារដ្ឋលេខាធិការក្រសួងសាធារណការ និងទូរគមនាគមន៍ ក្រៅពីបំពេញកិច្ចការ ក្រសួងសាមីលោក នូ ហាច បានឆ្លៀតឱកាសចុះសាកសួរសុខទុក្ខបងប្អូនប្រជាជន ពិនិត្យស្ថានភាពស្រុកទេសតាមបណ្តាខេត្តនានាផងដែរ។ ជាអាទិ៍ នៅចន្លោះថ្ងៃទី២១-២៣ តុលា១៩៥២ លោក នូ ហាច បាន អមព្រះរាជដំណើរទស្សនាការនៃសម្តេចក្រុមព្រះ មុនីរ៉េត ឧបនាយករដ្ឋមន្ត្រី (ប្រមុខក្រុមខេមរភូមិន្ទ) នៅខេត្តតាកែវ និងកំពត[២៤]។

លោក នូ ហាច ជាអ្នកការទូតមួយជាន់ខ្ពស់។ លោកធ្លាប់បំពេញភារកិច្ចការទូត មានឋានៈជាឯកអគ្គរដ្ឋទូតខ្មែរប្រចាំប្រទេសឥណ្ឌូណេស៊ី[២៥]។ លោក នូ ហាច បានបំពេញមុខតំណែងជាអ្នកការទូតចុង ក្រោយបង្អស់ក្នុងឋានៈជាឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ១៩៦៩។ លោកបានចូលនិវត្តន៍នៅឆ្នាំ១៩៧២[២៦]។

តាមរយៈពត៌មាននេះ គេអាចសន្និដ្ឋានបានថា លោក នូ ហាច បានបម្រើការរាជការក្នុង កំឡុងពេល ៣៣ឆ្នាំ ស្មើនឹង ៥៥,៩៣ ភាគរយ នៃជីវិត ៥៩ ឆ្នាំរបស់លោក ប្រសិនបើលោកត្រូវពួកខ្មែរក្រហម សម្លាប់នៅឆ្នាំ១៩៧៥។

ក្រៅពីតួនាទីខាងលើ លោក នូ ហាច ក៏បានចូលរួមចំណែកក្នុងសមាគមអ្នកនិពន្ធខ្មែរផងដែរ។ លោក នូ ហាច បានចូលរួមជាសមាជិកសមាគមអ្នកនិពន្ធខ្មែរតាំងពីថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៥[២៧]។ លោក យូ បូ

---

[២១]. សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២៣០ ដ៩ម ទំព័រ៧៧០៦។

[២២]. សូមមើល រាជកិច្ច ឆ្នាំទី១៧ លេខ២០៤ ថ្ងៃសៅរ៍ ទី១៦ កញ្ញា គស១៩៦១ ទំព័រ៦៧១៩។

[២៣]. សូមមើល ***JOURNAL OFFICIEL DU CAMBODGE,*** HUITIÉM ANNÉE N⁰25 JEUDI 26 JUIN 1952 p.1226.

[២៤]. ទស្សនាវដ្តីរូបភាព *កម្ពុជា* ក្រសួងឃោសនាការ ឆ្នាំទី១ ខែធ្នូ លេខ៤ ថ្ងៃទី១០ ធ្នូ ១៩៥២ ទំព័រ១០-១១។

[២៥]. សមាគមអ្នកនិពន្ធខ្មែរ *ប្រវត្តិអ្នកនិពន្ធខ្មែរ* ក្នុង *ទស្សនាវដ្តីអ្នកនិពន្ធខ្មែរ* ឆ្នាំទី២ លេខ៣ ខែកុម្ភៈ ឆ្នាំ១៩៩៦ ទំព័រ១៣។

[២៦]. Voir Khing Hoc Dy ***Ecrivains et expressions littéraires du Cambodge au XXéme siécle*** Op. cit. p.46.

[២៧]. Ib. id p.13.

ប្រធានសមាគមអ្នកនិពន្ធខ្មែរជំនាន់ទី៧ មានប្រសាសន៍កាលពីថ្ងៃសៅរ៍ ទី៨ ខែកុម្ភៈ ឆ្នាំ២០០៣ វេលាម៉ោងពីររសៀលថា លោក នូ ហាច ជាមនុស្សល្អ ស្លូតត្រង់ មានប្រជាប្រិយ ដោយលោកចូលចិត្តនិយាយចំៗ ឃើញយ៉ាងម៉េច ថាអញ្ចឹង។ លោក នូ ហាច បានចូលរួមធ្វើជាគ្រូបង្រៀនថ្នាក់បណ្តុះបណ្តាលអ្នកនិពន្ធវគ្គទី១ (រយៈពេលប្រាំបួនខែ ) និងវគ្គទី២ ( រយៈពេលពីរឆ្នាំ ) ដោយបង្រៀនវិធីសាស្ត្រតែងកាព្យបារាំង[២៨]។

## ៧- មរណភាព

តាមរយៈប្រសាសន៍លោកតា រី ទី បញ្ជាក់ថា លោក នូ ហាច ត្រូវបានគេសម្លាប់ក្នុងសម័យខ្មែរក្រហម។ កាលនោះខ្មែរក្រហមចូលមកដល់ថា អញ្ជើញគាត់ទៅប្រជុំ មិនយកទៅសម្លាប់ទេ ម្តាយក៏ឱ្យលោកឈឿ ទៅតាមមើលបង តែគេមិនយកទៅប្រជុំ បែរជាយកទៅសម្លាប់ចោល។

អ្នកមីង រុំ ឌី បានប្រាប់ឱ្យដឹងពីមូលហេតុនៃមរណភាពរបស់លោក នូ ហាចនេះថា ពួគេថា ឱ្យគាត់ទៅវាស់ដី អ៊ុំឈឿ ក៏សុំគេទៅជាមួយបងថាបងចាស់ គេក៏វាយចោលទាំងពីរនាក់បងប្អូន (យោធា និយាយថា ហេតុតែបងប្អូន មិនដឹងគេយកបងទៅសម្លាប់) នៅភ្នំពេញ (ខ្លះថាម្តុំវត្តលង្កា ខ្លះថាម្តុំ ព្រែកលៀប)។

លោក នូ ហាច បាត់ខ្លួនក្រោយពេលប្រទេសខ្មែរធ្លាក់ចូលក្នុងកណ្តាប់ដៃរបបកម្ពុជាប្រជាធិបតេយ្យ។ លោកក៏មានវាសនាអាក្រក់ដូចប្រជាជនខ្មែរដទៃទៀតនៅក្នុងប្រទេសដែរ។ មជ្ឈដ្ឋានអ្នកសិក្សា សន្និដ្ឋានថា ការបាត់ខ្លួនរបស់លោក នូ ហាច ប្រហែលជាត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលក្នុងពេលកាន់អំណាច (ចន្លោះឆ្នាំ១៩៧៥-១៩៧៩) ដូចប្រជាជនខ្មែរឯទៀតៗដែរ។

## ៨- ស្នាដៃ

លោក នូ ហាច ជាអ្នកនិពន្ធខ្មែរដ៏ល្បីល្បាញមួយរូបមុនសម័យខ្មែរក្រហម។ ក្នុងវិស័យតែងនិពន្ធ គេរកឃើញប្រលោមលោកផ្នែកមនោសញ្ចេតនាចំនួនប្រាំរឿង និពន្ធឡើងដោយលោក នូ ហាច។ ស្នាដៃទាំងនោះគឺៈ

| | | |
|---|---|---|
| -រឿងផ្កាស្រពោន | និពន្ធឆ្នាំ ១៩៤០ | បោះពុម្ពឆ្នាំ១៩៤៩ |
| -រឿងមាលាដួងចិត្ត | និពន្ធឆ្នាំ ១៩៥២ | បោះពុម្ពឆ្នាំ១៩៧២ |
| -រឿងនារីជាទីស្នេហា | និពន្ធឆ្នាំ ១៩៥៣ | បោះពុម្ពឆ្នាំ១៩៥៣ |
| -រឿងលាវណ្យនិងរិទ្ធ | និពន្ធឆ្នាំ ១៩៥៣ | បោះពុម្ពឆ្នាំ១៩៥៥ |
| -រឿងគ្រួយជីវិត | និពន្ធឆ្នាំ ? | បោះពុម្ពឆ្នាំ១៩៧៣ |

ព្រមទាំងអត្ថបទរឿងខ្លីៗ អត្ថបទកំណាព្យខ្លីៗ មួយចំនួនទៀត។
តែជាប្រការគួរឱ្យសោកស្តាយដែលមកដល់ពេលបច្ចុប្បន្ននេះ ស្នាដៃមួយចំនួនរបស់អ្នកនិពន្ធ នូ ហាច ត្រូវបានបាត់បង់រកដានមិនឃើញ។ ស្នាដៃដែលបាត់បង់ទាំងនោះ មានជាអាទិ៍ រឿងលាវណ្យនិងរិទ្ធ រឿងនារីជាទីស្នេហា រឿងគ្រួយជីវិត ជាដើម។

---

[២៨]. ការសម្ភាសន៍លោក យូ បូ ប្រធានសមាគមអ្នកនិពន្ធខ្មែរជំនាន់ទី៧ ថ្ងៃសៅរ៍ ទី៨ ខែកុម្ភៈ ឆ្នាំ២០០៣។

# ឯកសារពិគ្រោះ

**ស្នាដៃបោះពុម្ពផ្សាយ និងនិក្ខេបបទ**

**ល.រ អ្នកនិពន្ធ ឈ្មោះសៀវភៅ ពេលពុម្ព ឆ្នាំ**


១. ក្រុមអ្នកចងក្រង ៖ សំរាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ ? ១៩៨៦

៣. គីន ណាន ៖ ក្រមុំចូលម្លប់និងពិធីរើសគូស្រករ ?១៩៨២

៤. គឹមសែត ៖ ប្រវត្តិអក្សរសាស្ត្រ ? ?

៥. យឹង ហុកឌី ៖ ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ ដេ៊ិតឿនស ល៍គារមោគតាន១៩៩៧

៦. យីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី១៩, បណ្ណាគារអង្គរ,២០០៧

៧. យីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី២០, បណ្ណាគារអង្គរ,២០០៧

៨. យឹម សាគុណ ៖ សិទ្ធិមនុស្សតាមរយៈអក្សរសិល្ប៍ខ្មែរ ?១៩៨២

៩. យឹម សំឱ ៖ប្រវត្តិអក្សរសាស្ត្រខ្មែរ ?១៩៦១

១០. ឃួន សុខម្ភៈ ប្រវត្តិអ្នកនិពន្ធខ្មែរ ? ?

១១. ង៉ុយ ៖ ច្បាប់ក្រមង៉ុយ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧២,២៥១៦

១២. ជួន ណាត ៖ វចនានុក្រមខ្មែរភាគ១-២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧

១៣. (ព្រះអង្គ) ឌួង ៖ ច្បាប់ស្រី ពុទ្ធសាសនបណ្ឌិត្យ ១៩៦២,២៥០៥

១៥. ត្រឹង ងា,ប្រវត្តិសាស្ត្រខ្មែរ, ភាគ១ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤

១៦. ត្រឹង ងា ៖ ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤,២៥១៨

១៩. ធ សោ ៖ លក្ខណៈទីពីកក្នុងអក្សរសិល្ប៍ និងសិល្បៈខ្មែរ មេរៀនសរសេរដៃ ២០០២

២០. ហ៊ុន គឹមសៀ ៖ មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ ? ?

២១. ពៅ សាមី ៖ លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ

២២. ពៅ សាមី ៖លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ

២៣. ពៅ សាមី ៖ តថនិយមក្នុងអក្សរសិល្ប៍ខ្មែរសតវត្សទី២០

២៤. ពៅ សាមី ៖ មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៧

២៥. រស់ ចន្ត្រាបុត្រ ៖ អំពីស្នេហា សារពត៌មានមហាជន ១៩៧១

២៦. លាង ហ័បអាន ៖ សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ភាគ១ ?១៩៦៧

២៧. លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ១ ?១៩៦៦

២៨. លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ២ ?១៩៦៦

២៩. លាង ហាប់អាន ៖ ប្រជុំវិញ្ញាសាតែងសេចក្តីគំរូសំរាប់ថ្នាក់ទី៥.៤.៣ ទំនើប ?

៣០. លាង ហាប់អាន ៖ សិក្សាសង្ខេបរឿងកុលាបប៉ៃលិន ??

៣១. លី ធាមតេង ៖ អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី បណ្ណាល័យអប្សរា សមាគមអ្នកនិពន្ធខ្មែរ ១៩៧២

៣២.លី សុមុនី, កំណាព្យខ្មែរ, ក្រសួងអប់រំយុវជន និង កីឡា, ២០០២
៣៣. វ៉ាន់ឌី កាអុន ៖ វិភាគទាននៃក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ ??
៣៤. វ៉ាន់ឌី កាអុន ៖ក្បួនចិត្តសាស្រ្ត ?១៩៧៣
៣៥. វ៉ាន់ឌី កាអុន ៖វិភាគទានក្នុងការសិក្សាប្រាកដនិយមនិងអណ្តែតអណ្តូងនិយម ?១៩៧៣
៣៦. វ៉ាន់ឌី កាអុន ៖សង្គមសាស្រ្ត ?១៩៧៣
៣៧. ស៊ន សំណាង (E.d.) ៖ ខេមរវិទ្យា ចំណេះដឹងអំពីអតីតកាល និង ការរួមវិភាគទានក្នុងការស្តារ និង ស្ថាបនាប្រទេសកម្ពុជាឡើងវិញ ភាគ២ រោងពុម្ពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៩
៣៨. សម្ព័ន្ធអ្នកសារពត៌មាន រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ១៩៤៧ ដល់ឆ្នាំ១៩៩៣ ??
៣៩. សមាគមអ្នកនិពន្ធខ្មែរ ៖ ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធសមាជិកនៃសមាគម ១៩៧០
៤០. សមាគមអ្នកនិពន្ធបទភ្លេង នឹងទំនុកច្រៀង ៖លក្ខន្តិកៈ ? ១៩៦២
៤១. សោម សុមុនី ៖ អក្សរសិល្ប៍ពាក្យរាយខ្មែរ និក្ខេបបទថ្នាក់បណ្ឌិត, សំណេរដៃ, ?
៤២. សែម សូរ ៖ វិជ្ជានិពន្ធន៍ខ្មែរចម្រុះ បណ្ណាគារភ្នំពេញ, ១៩៦៣
៤៣. ស៊ុំ ឈុំប៊ុន ៖ តួអង្គក្នុងអក្សរសិល្ប៍ទំនើបខ្មែរ ពីទសវត្សទី៤០ ដល់ទី៦០ និក្ខេបបទថ្នាក់បណ្ឌិត, ?
៤៤. ស៊ុំ ឈុំប៊ុន ៖ អក្សរសិល្ប៍ខ្មែរ សម័យទំនើប មេរៀនសរសេរដៃ, ២០០២
៤៥. ស៊ុំ ឈុំប៊ុន ៖ គោលសង្ខេបនៃការសិក្សាប្រវត្តិអក្សរសិល្ប៍ខ្មែរ មេរៀនសរសេរដៃ, ២០០២
៤៦. អ៊ុក ចួន ៖ ចំណោទ និងសំរាយបញ្ហាក្នុងអក្សរសិល្ប៍ខ្មែរ សកព, ១៩៨៨
៤៧. អ៊ុក សាម៉ន ៖ សិក្សាកថារឿងទុំ-ទាវ បណ្ណាគារភ្នំពេញ, ១៩៦៦,២៥០៨
៥៤. Klairung Amratisha: *The Cambodian Novel,A study of its Emergence and Development* ?1998
៧៩. អក្សរសាស្រ្ត-មនុស្សសាស្រ្ត, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ លេខ១៩ ត្រីមាសទី៣ ឆ្នាំ២០០២
៨០. ឯកសារ ៖ សន្និសីទជាតិស្តីពី ការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ៖ តុល្យការ និង ចក្ខុវិស័យ រាជបណ្ឌិតសភាកម្ពុជា ២០០០

## អត្ថបទរឿង

**ល.រ ឈ្មោះអ្នកនិពន្ធ ឈ្មោះអត្ថបទ ផ្សាយពី រោងពុម្ព កាលបរិច្ឆេទ**

៨២. គឹម ហាក់ ទឹកទន្លេសាប ? ១៩៣៦
៨៣. ឃីង ហុក ឌី, ទាវឯក, បណ្ណាគារអង្គរ,២០០៥។
៨៤. ញ៉ុក ថែម កុលាបប៉ៃលិន គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ក្រ.អ.យ.ក. ២០០១,២៥៤៥
៨៥. នូ ហាច ផ្កាស្រពោន ក្រសួងសិក្សាធិការជាតិ រោងពុម្ពរស្មី១៩៦០.២៥០៣
៩០. នូ ហាច មាលាដួងចិត្ត មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌ខ្មែរ១៩៨១
៩២. នូ ហាច មាលាដួងចិត្ត ឯកសារប្រើប្រាស់ផ្ទៃក្នុង សាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៩
៩៣. រីម គីន សូផាត បណ្ណាគារ សេង ងួនហួត ភ្នំពេញ ១៩៦៥,២៥០៧
៩៤. រីម គីន នាងសមាភារី បណ្ណាល័យជាតិ ភ្នំពេញ ២០១៣

៩៥. សោម ទុំទាវ  ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧១,២៥១៤
៩៦. ស្ទេក ស្តៀ រ៉ូមេអូ និង ស៊ុលីយែត ប្រែសម្រួលដោយ ហង្ស ធុនហាក់ រោងពុម្ពសារពត៌មាននគរធំ ១៩៧១
៩៧. ចៅភក្តី៨ក ហង្សយន្ត ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៩៨,២៥៤២
៩៨. ប៉ូល វីរហ្សីនី  ប្រែសម្រួលដោយ ហង្ស ធុនហាក់ ??